6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia

Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: cert.malaysia@moodyint.com
www.intertek.com, www.moodyint.com;

MICM លេខយោង: RSPO-02-07102011/11-2

23 MARCH 2012

*ភាគីពាក់ព័ន្ធជាទីគោរព!*

<u>ការអញ្ជើញដើម្បីធ្វើការអត្ថាធិប្បាយលើ ការវាយតម្លៃក្នុងការផ្តល់វិញ្ញាបនបត្ររបស់សមាគម RSPO ដល់កសិដ្ឋានចំការដូងប្រេងនៃក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា ក្នុងនោះផ្នែកដែលត្រូវធ្វើការវាយតម្លៃរួមមាន៖ រោងចក្រចំរាញ់ដូងប្រេង និងកសិដ្ឋាន ដែលស្ថិតនៅក្នុងខេត្ត ព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា</u>

ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា (ដែលតទៅនេះហៅកាត់ថា 'MRICOP') បានដាក់ពាក្យទៅស្ថាប័នវិញ្ញាបនបត្រនៃប្រទេសម៉ាឡេស៊ី Moody International Certification (Malaysia) Sdn Bhd ដើម្បីធ្វើការវាយតម្លៃសំរាប់វិញ្ញាបនបត្រនៃសមាគម RSPO ទៅលើអង្គភាពដែលនឹងទទួលវិញ្ញាបនបត្រ ដែលស្ថិតនៅខេត្ត ព្រះសីហនុ ប្រទេសកម្ពុជា ដោយផ្អៀបទៅនឹងគោលការណ៍ និងលក្ខណវិនិច្ឆ័យនៃសមាគម RSPO សំរាប់ក្រុមប្រទេសដែលផលិតបានតិច (SPC)។

ក្រុមហ៊ុន MRICOP គឺជាក្រុមហ៊ុនដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជា ធ្វើកសិកម្មដូងប្រេងបែបពាណិជ្ជកម្ម ដែលបានទទួលការលើកទឹកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា។ ក្រុមហ៊ុន MRICOP បានទទួលដីសម្បទានសេដ្ឋកិច្ចចំនួន ១១,០០០ ហិកតា ដែលមានទីតាំងនៅស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ ប្រទេស កម្ពុជា សំរាប់ធ្វើការអនុវត្តន៍តាមគោលបំណងខាងលើ។ ទីតាំងគំរោងគឺនៅប្រវែងប្រហែល ១៥៨ គីឡូម៉ែត្រ ខាងត្បូងពីរាជធានីភ្នំពេញ និង ៧០ គីឡូម៉ែត្រ ខាងជើងពីក្រុងកំពង់ផែព្រះសីហនុ។

រោងចក្រចំរាញ់ប្រេងដូងនៅត្រូវបានដាក់អោយដំណើរការនៅក្នុងឆ្នាំ ២០០២។ បច្ចុប្បន្នក្រុមហ៊ុន MRICOP គ្រប់គ្រងរោងចក្រចំរាញ់ប្រេងដូងមួយ និងកសិដ្ឋានចំនួនពីរដែលផ្គត់ផ្គង់ផ្លែដូងស្រស់ ដូចជា៖ កសិដ្ឋាន អេ និងកសិដ្ឋាន ប៊ី។ ក្រុមហ៊ុន MRICOP មានភាពជាម្ចាស់មួយផ្នែកនៃកសិដ្ឋានទីបី គឺកសិដ្ឋាន ស៊ី ដែលជាសម្ព័ន្ធអាជីវកម្មមួយ ដោយស្ថិតនៅក្រោមក្រុមហ៊ុនមួយឈ្មោះ MTSI ហើយដែលការដាំដុះថ្មីកំពង់ដំណើរការ។ ដូចនេះ ក្រុមហ៊ុន MRICOP បានធ្វើផែនការសំរាប់បីកសិដ្ឋាន ក្នុងការទទួលអោយបានវិញ្ញាបនបត្រនៅក្នុងផែនការកំណត់ពេលវេលា បី ឆ្នាំ ដោយបញ្ចប់នៅក្នុងឆ្នាំ ២០១៥។

ស្ថាប័ន Moody International Certification មានផែនការធ្វើការវាយតម្លៃទៅលើការផ្តល់វិញ្ញាបនបត្រដ៏សំខាន់តាមការស្នើសុំ ដែលនឹងចាប់ផ្តើមនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ និងបញ្ចប់នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១២។

Intertek MOODY INTERNATIONAL

6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia
Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: cert.malaysia@moodyint.com
www.intertek.com, www.moodyint.com;

សេចក្តីពិស្តារ នៃរោងចក្រចំរាញ់ប្រេងដូង និងកសិដ្ឋាន ដែលនឹងត្រូវធ្វើការវាយតម្លៃគឺមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ | អាសយដ្ឋាន / ទីតាំង | លេខយោង GPS | |
|---|---|---|---|
| | | រយៈទទឹង | រយៈបណ្តោយ |
| រោងចក្រចំរាញ់ប្រេងដូង (សមត្ថភាព: ៣០តោន/១ម៉) | ការិយាល័យកណ្តាល:<br>#៥២, ផ្លូវ ៤៩៨ សង្កាត់ បឹងកក់ពីរ ខណ្ឌ ទួលគោក រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>Website: www.mricop.com.kh<br>ការិយាល័យនៅចំការ:<br>ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា ផ្លូវជាតិលេខ ៤, ឃុំ ជើងគោ ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា | ១២.០៥៥០° N | ៣៧.២៥០០° E |
| កសិដ្ឋាន អេ | ដូចខាងលើ | ១១.៩៨០០° N | ៣៦.៧០០០° E |
| កសិដ្ឋាន ប៊ី | ដូចខាងលើ | ១២.០២០០° N | ៣៧.៥០០០° E |
| កសិដ្ឋាន ស៊ី | ដូចខាងលើ | ១២.០៨០០° N | ៣៧.៦០០០° E |

| កសិដ្ឋាន | សង្ខេបផ្ទៃដី(ហ.ត) | |
|---|---|---|
| | សរុប | ដាំរួច |
| កសិដ្ឋាន អេ | ៥.៩៦៧ | ៥.០៧៨ |
| កសិដ្ឋាន ប៊ី | ៣.០៨៨ | ២.៩៩១ |
| កសិដ្ឋាន ស៊ី | ៦.៦៤២ | ៤.៦៤២ |
| សរុប | ១៥.៦៩៧ | ១១.៧០៧ |

| អាយុ (ឆ្នាំ) | ផ្ទៃដីដែលបានដាំរួច (ហ.ត) | | |
|---|---|---|---|
| | កសិដ្ឋាន អេ (ហ.ត) | កសិដ្ឋាន ប៊ី (ហ.ត) | កសិដ្ឋាន ស៊ី (ហ.ត) |
| ០ – ៣ | ៨១ | ៦៤២ | ៤.៦៤២ |
| ៤ – ១៥ | ៣.៩៩៣ | ២.៣៤៩ | ០ |
| លើ ១៥ | ០ | ០ | ០ |
| សរុប | ៥.០៧៨ | ២.៩៩១ | ៤.៦៤២ |

Intertek MOODY INTERNATIONAL

6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia

Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: cert.malaysia@moodyint.com
www.intertek.com, www.moodyint.com

កំណត់ចំណាំ:

១. កសិដ្ឋាន អេ និង ប៊ី បានចាប់ផ្តើមដាំតាំងពីឆ្នាំ ១៩៩៧ ហើយរហូតមកដល់បច្ចុប្បន្ននេះគឺស្ថិតនៅក្នុងវដ្តទី១ នៃការដាំ ខណៈឯ កសិដ្ឋាន ស៊ី បានចាប់ផ្តើមដាំតាំងពីឆ្នាំ ២០០៨ មក។

២. ពីមុនមក កសិដ្ឋាន ស៊ី គឺជាចំការដែលដាំដំណាំកសិកម្មដទៃទៀតតាំងពីឆ្នាំ ១៩៩៧ ហើយក្រោយមកត្រូវបានកែប្រែមកដាំដំណាំដូងប្រេងវិញ ដោយមានការបង្កើតថ្នាលបណ្តុះកូនប្រេងដូងនៅក្នុងឆ្នាំ ២០០៨។ ដូងប្រេងនៅក្នុងកសិដ្ឋាន ស៊ី គឺនៅក្នុងដំណាក់កាលមិនទាន់ពេញវ័យ។

៣. ក្រុមហ៊ុន MRICOP ជាមួយនឹងសម្ព័ន្ធអាជីកម្មរបស់ខ្លួននឹងក្រុមហ៊ុន MTSI មានផែនការកសាងរោងចក្រចំរាញ់ប្រេងដូងនៅមួយផ្សេងទៀតអោយរួចរាល់នៅឆ្នាំ ២០១៣ ដើម្បីទទួលការផ្គត់ផ្គង់ផ្លែដូងស្រស់ពីកសិដ្ឋាន ស៊ី។

ទិន្នផលសរុបជាក់ស្តែងរយៈពេល ១២ ខែចុងក្រោយដូចដែលបានបញ្ជាក់ពីក្រុមហ៊ុន MRICOP (នោះគឺ ពីខែ មិនា ឆ្នាំ ២០១១ រហូតដល់ខែ កុម្ភៈ ឆ្នាំ ២០១២) គឺមានបង្ហាញនៅក្នុងតារាង ១ ខាងក្រោម ៖

តារាង ១: ទិន្នផលផ្លែដូងស្រស់ និងការផលិតផលិតផលពីដូងប្រេងសរុប

| ឈ្មោះកសិដ្ឋាន | ទីតាំង | បរិមាណប្រចាំឆ្នាំ (តោន) | | | |
|---|---|---|---|---|---|
| | | ផ្លែដូងស្រស់ផ្គត់ផ្គង់ពីកសិដ្ឋាន PMU | ផ្លែដូងស្រស់ផ្គត់ផ្គង់ពីអ្នកផ្គត់ផ្គង់ផ្សេងទៀត (ប្រសិនបើមាន) | ទិន្នផលប្រេងឆៅ ទិន្នផលចំរាញ់សរុប | ទិន្នផលគ្រាប់ដូង ទិន្នផលបំបែកសរុប |
| កសិដ្ឋាន អេ | ដូចខាងលើ | ៦៩.៨១៨,១៨ | 0,00 | ១៣.៣២៥,៤០ | ២.៣៣០,២៦ |
| កសិដ្ឋាន ប៊ី | ដូចខាងលើ | ២៨.២៦៦,៧៤ | 0,00 | ៥.៣៩៤,៦៧ | ៩៣៥,៤៦ |
| | សរុប | ៩៨.០៨៤,៩២ | 0,00 | ១៨.៧២០,០៧ (អត្រាចំរាញ់ប្រេង ១៩,០៨ %) | ៣.២៦៥,៧២ (អត្រាទាញយកគ្រាប់ ៣,៣៣ %) |

សំគាល់៖ សេចក្តីពិស្តារខាងលើដូចដែលបានផ្តល់ដោយក្រុមហ៊ុន MRICOP នឹងត្រូវស្ថិតនៅក្រោមការបញ្ជាក់នៅក្នុងអំឡុងពេលវាយតម្លៃនៅទីតាំងគំរោង។

បច្ចុប្បន្ននេះ ស្ថាប័នផ្តល់វិញ្ញាបនបត្រនៃប្រទេសម៉ាឡេស៊ី Moody International Certification (Malaysia) Sdn Bhd គឺជាផ្នែកមួយនៃគ្រុប Intertek Moody Group។ Interteck Moody Group គឺជាអង្គការមួយក្នុងចំណោមអង្គការអន្តរជាតិដែលឈានមុខគេ ក្នុងការផ្តល់វិញ្ញាបនបត្រខាងប្រព័ន្ធគ្រប់គ្រង ដោយសំដៅទៅលើគុណភាព បរិស្ថាន សុវត្ថិភាព និងសុខភាពការងារ និងការបញ្ជាក់ពីផលិតផល ខាងបណ្តាញគាំពារផ្នែកជើងទឹកប្រកបដោយចីរភាព ខាងការបញ្ជាក់ទៅលើបណ្តាញគាំពារការលើកទឹកចិត្តការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពនៅក្នុងវិស័យឧស្សាហកម្មដែលអាចអនុវត្តបាន រួមទាំងវិស័យកសិកម្ម

6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia
Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: cert.malaysia@moodyint.com
www.intertek.com, www.moodyint.com;

និងព្រៃឈើ។ Intertek Moody មានបទពិសោធន៍ជាង ១០០ ឆ្នាំ ក្នុងការផ្តល់ប្រភេទផ្សេងៗគ្នាជាច្រើននៃការត្រួតពិនិត្យ និងការធ្វើវិញ្ញាបនកម្ម នៅក្នុងប្រទេសជាង ១០០ ទូទាំងសកលលោក។ ជាគ្រួបមួយ Intertek Moody ត្រូវបានប្រគល់សិទ្ធិជាច្រើនវិស័យដោយស្ថាប័នឈានមុខគេនៃពិភពលោកខាងការផ្តល់ការទទួលស្គាល់ជាមាត្រដ្ឋានដូចជា៖ ស្ថាប័ន UKAS (ចក្រភពអង់គ្លេស) COFRAC (ប្រទេសបារាំង) Dakks (ប្រទេសអាល្លឺម៉ង់) ACCREDIA (ប្រទេសអ៊ីតាលី) Marine Stewardship Council (MSC/ASI) និង STANDARDS MALAYSIA (ប្រទេសម៉ាឡេស៊ី) សំរាប់ប្រព័ន្ធផ្តល់វិញ្ញាបនបត្រដែលទទួលស្គាល់ច្បាស់លាស់។

ក្រុមវាយតម្លៃ ដែលមានផែនការសំរាប់ការវាយតម្លៃក្នុងការផ្តល់វិញ្ញាបនបត្រ រួមមានអ្នកដឹកនាំវាយតម្លៃ គឺលោក Augustine Loh (ទទួលបន្ទុកខាងប្រតិបត្តិការរោងចក្រ បរិស្ថាន សុវត្ថិភាព និងសុខភាព និងច្បាប់), លោក Mohan Thavarajah (ទទួលបន្ទុកប្រតិបត្តិការរោងចក្រ បរិស្ថាន សុវត្ថិភាព និងសុខភាព និងច្បាប់), អ្នកស្រី Ham Fin Lan (ទទួលបន្ទុកខាងបញ្ហាសង្គម, យេនឌ័រ រួមទាំងសុខមាលភាពស្ត្រី), លោក Chen Fai Kok (ទទួលបន្ទុកខាងការអនុវត្តន៍ការធ្វើកសិកម្មដ៏ល្អបំផុត វិធានការចំរុះថែទាំដំណាំ និងតំបន់ដែលមានតម្លៃខ្ពស់សំរាប់ការអភិរក្ស - HCV) និង លោក Reaksa Rous (អ្នកជំនាញក្នុងស្រុកទទួលបន្ទុកខាងច្បាប់ និងបទបញ្ញត្តិជាតិ) ។

ក្នុងគោលបំណងនៃការធ្វើការវាយតម្លៃផ្តល់វិញ្ញាបនបត្រនៅឯទីតាំងដូចដែលបានចែងខាងលើ ដែលនឹងឈានមកដល់នេះ Moody International Certification (Malaysia) Sdn Bhd សូមស្វាគមន៍ភាគីពាក់ព័ន្ធទាំងឡាយក្នុងការផ្តល់សេចក្តីអត្ថាធិប្បាយ (ប្រសិនបើមាន) ទៅលើបញ្ហាខាងក្រោម ដែលពាក់ព័ន្ធទៅនឹងចំការសំរាប់ធ្វើការវាយតម្លៃ៖

- ការការពារបរិស្ថាន
- ឱកាសការងារ
- បញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃ
- ការអភិរក្សជីវចម្រុះ
- ការអភិវឌ្ឍន៍សហគមន៍

រាល់សេចក្តីអត្ថាធិប្បាយត្រូវបានទទួលក្នុងរយៈពេល ៣០ ថ្ងៃ ដោយចាប់ពីថ្ងៃដែលលិខិតនេះនឹងត្រូវបានរាប់បញ្ចូលទៅក្នុងការវាយតម្លៃផ្តល់វិញ្ញាបនបត្រ។ ដូច្នោះសូមផ្តល់សេចក្តីអត្ថាធិប្បាយរបស់លោកអ្នកទៅ៖

លោក Augustine Loh
ប្រធានកម្មវិធី
Moody International Certification (Malaysia) Sdn Bhd
6-L12-01, Level 12, Tower 2, Menara PGRM,
No. 6 & 8, Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia
Tel: 603 9283 9881 Fax: 603 9284 8187
Email: augustine.loh@intertek.com

លោក Sumate Pratumsuwan
នាយករងគ្រប់គ្រងទូទៅ/ប្រធានក្រុមដឹកនាំគំរោង RSPO
Mong Reththy Investment Cambodia Oil Palm Co. Ltd
#52, St. 598 Sangkat Boeung Kak II , Khan Toul Kork,
Phnom Penh, Kingdom of Cambodia.
Tel: (855) 23986438 Fax: (855) 23986439
Email: sumatep@gmail.com

Intertek
MOODY INTERNATIONAL

6-L12-01, Level 12, Tower 2,
Menara PGRM
No. 6 & 8 Jalan Pudu Ulu, Cheras,
56100 Kuala Lumpur, Malaysia

Telephone: +00 (603) 9283 9881
Facsimile: +00 (603) 9284 8187
Email: cert.malaysia@moodyint.com
www.intertek.com, www.moodyint.com;

យើងសូមថ្លែងអំណរគុណដល់លោកអ្នកសំរាប់ការធ្វើអត្ថាធិប្បាយ និងយោបល់ត្រឡប់របស់លោកអ្នក។

ដោយសេចក្តីគោរព
Moody International Certification (Malaysia) Sdn Bhd.

Chin Miew Lim K.M.N.
ប្រធានតំណាងប្រទេស